**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ១០៦ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការកាត់ឆ្វៀលដីទំហំ ៥ហិកតា ចេញពីស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើគ្រពាំងធំ ស្ថិតនៅឃុំព្រៃស្លឹក ស្រុកទ្រាំង ខេត្តតាកែវ ដើម្បីធ្វើអនុប្បយោគជាដីឯកជនរបស់រដ្ឋ ជូនការិយាល័យទី២ កងទ័ពជើងគោក នៃក្រសួងការពារជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២២/១២៣៦ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២ ស្ដីពីការតែងតាំងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រា១.-**

ត្រូវបានកាត់ឆ្វៀលដីទំហំ ៥(ប្រាំ)ហិកតា ចេញពីស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើគ្រពាំងធំ ស្ថិតនៅឃុំព្រៃស្លឹក ស្រុកទ្រាំង ខេត្តតាកែវ ដើម្បីធ្វើអនុប្បយោគជាដីឯកជនរបស់រដ្ឋ ជូនការិយាល័យទី២ កងទ័ពជើងគោក នៃ

ក្រសួងការពារជាតិ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទីបង្ហាញទីតាំងដី និងចំណុចនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២._**

ប្រគល់អាណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនក្រសួងការពារជាតិ ដើម្បីធ្វើការគ្រប់គ្រង និងចាត់ចែងស្របតាមនីតិវិធីជាធរមាន។

**មាត្រា៣._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តតាកែវ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១១កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ផែនទី ទីតាំងដីដែលត្រូវកាត់ឆ្វៀលទំហំ ៥ហិកតា ស្ថិតនៅឃុំព្រៃស្លឹក ស្រុកត្រាំង ខេត្តតាកែវ ចេញពីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើត្រពាំងធំ**
**ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ជូនការិយាល័យទី២ កងទ័ពជើងគោក នៃក្រសួងការពារជាតិ**

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ** ១០៦ **អនក្រ.បក ចុះថ្ងៃ** អង្គារ ១១ កើត **ខែ** ជេស្ឋ **ឆ្នាំ**ថោះ បញ្ចស័ក ព.ស.២៥៦៧ **ត្រូវនឹងថ្ងៃទី** ៣០ **ខែ** ឧសភា **ឆ្នាំ**២០២៣




| ចំណុចនិយាមកា | | |
|---|---|---|
| N | X | Y |
| 1 | 473648 | 1202998 |
| 2 | 473845 | 1202964 |
| 3 | 473976 | 1203197 |
| 4 | 473765 | 1203214 |